**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**សាលក្រមព្រហ្មទណ្ឌ**
លេខ ៣២ (ញ)/៣០៣
ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ២៤
ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២២
-សំណុំរឿងស៊ើបសួរលេខ ១៣
ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២២
-សំណុំរឿងជំនុំជម្រះលេខ ២៨៥
ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

| | |
|---|---|
| កាលបរិច្ឆេទនៃសវនាការជាអសាធារណៈ | ៖ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០២២ |
| សាលសវនាការ និងពេលវេលា | ៖ សាលលេខ ខ២ នៅម៉ោង៨:៣០ព្រឹក |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២២ |
| សាលសវនាការ និងពេលវេលា | ៖ សាលលេខ ខ១ នៅម៉ោង៩:០០ព្រឹក |

ក្រោមសមាសភាពជំនុំជម្រះ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូង

**ដើម្បីជំនុំជម្រះលើ**

សំណុំរឿងព្រហ្មទណ្ឌលេខ ២៤ ចុះថ្ងៃទី៦ ខែ មករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ ៖

**១/-ឈ្មោះ** [redacted] **សីហា** ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី១ ខែសីហា ឆ្នាំ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តបាត់ដំបង មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី១១ មុខរបរ សិស្ស នៅលីវ ឪពុកឈ្មោះ [redacted] ម៉ាណុន (រ) ម្តាយឈ្មោះ [redacted] វី (រ) ទោសពីមុន គ្មាន (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩ ឃខ/ឋ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២

-លោក [redacted] ជាមេធាវីការពារសិទ្ធិ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ ។

**២/-ឈ្មោះ** [redacted] **តុងតុង** ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តសៀមរាប

កម្រិតវប្បធម៌ថ្នាក់ទី១១ មុខរបរ សិស្ស នៅលីវ ឪពុកឈ្មោះ [redacted] រស្មី (រ) ម្តាយឈ្មោះ [redacted] តាំង (រ) ទោសពីមុន គ្មាន (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩ យខ/ឋ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២

-លោក [redacted] ជាមេធាវីការពារសិទ្ធិ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ ។

ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **លួច (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅភូមិអន្លង់ពីរ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

## ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី

-ឈ្មោះ [redacted] **វល័ក្ខ** ភេទស្រី អាយុ១៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅបច្ចុប្បន្ននៅភូមិក្បូន ឃុំខ្វាស់ ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

## អង្គហេតុដែលប្តឹងមកតុលាការ

កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១១ និង ៣០ នាទី នៅចំណុចភូមិអន្លង់ពីរ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានករណី **លួច (ឆក់ទូរស័ព្ទ)** ដែលបង្កឡើងដោយជនសង្ស័យពីររូប មានឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] **តុងតុង** ភេទប្រុស អាយុ ១៧ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាកហុងដា ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១០ ធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃមួយគ្រឿង ដែលជារបស់ជនរងគ្រោះឈ្មោះ [redacted] **វល័ក្ខ** ភេទស្រី អាយុ១៨ឆ្នាំ ក្នុងពេលដែលជនរងគ្រោះបានដាក់ទូរស័ព្ទដៃនៅក្នុងហោប៉ៅខោខាងក្រោយ (ពេលកំពុងជិះម៉ូតូ) ។ ចំពោះសកម្មភាពឆក់វិញ គឺឈ្មោះ [redacted] **សីហា** ជាអ្នកឆក់ ចំណែកឯជនសង្ស័យឈ្មោះ [redacted] **តុងតុង** ជាអ្នកបើកបរម៉ូតូ ។ ក្រោយពីឆក់ទូរស័ព្ទបានហើយជនសង្ស័យ ទាំងពីររូបខាងលើ បាននាំគ្នាជិះម៉ូតូគេចខ្លួន ហើយក៏ត្រូវជនរងគ្រោះជិះម៉ូតូដេញតាមពីក្រោយ ។ លុះមកដល់ចំណុចហួសផ្សារដំដែក ប្រហែលជាមួយគីឡូម៉ែត្រស្រាប់តែឃើញសមត្ថកិច្ចចម្រុះដាក់បារ៉ាស់ផ្លូវ ហើយជនសង្ស័យបានបើកម៉ូតូបំបុកប៉ារ៉ាស់នោះ បណ្តាលឱ្យរងរបួសទាំងពីរនាក់ និងត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ហើយកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តសៀមរាប ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-**បានឃើញ** ពាក្យបណ្តឹង ចុះថ្ងៃទ៥ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] វល័ក្ខ ។

-**បានឃើញ** ពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] វល័ក្ខ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **១៨៥ អយក/២២** ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ ១៣៤៤ ពស.ព្រស/ឋ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

-**បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ **២៦០ ពស. ព្រជ(ក)** ចុះថ្ងៃទី៦ខែមេសា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។



Scanned with CamScanner

## **នាពេលសាកសួរ**

- ជនជាប់ចោទឈ្មោះ[redacted]**តុងតុង** បានឆ្លើយថា កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១១ និង៣០ នាទីថ្ងៃត្រង់ ខ្លួននិងឈ្មោះ [redacted] **សីហា** ភេទប្រុស ជាមិត្តភក្តិរបស់ខ្លួន បាននាំគ្នាជិះម៉ូតូទៅខេត្តកំពង់ធំ ដោយខ្លួនជាអ្នកបើកបរម៉ូតូ ដើម្បីទៅយកមិត្តភក្តិផង។ លុះជិះម៉ូតូដល់ស្រុកប្រាសាទបាគង ខ្លួនឃើញក៏បានជួបឈ្មោះ **វល័ក្ខ** ជាអ្នកស្គាល់គ្នា និងជាអ្នកដែលខ្លួនធ្លាប់ទាក់ទងផងដែរ ។ ខ្លួនបានឃើញទូរស័ព្ទដាក់ក្នុងហៅប៉ៅខោខាងក្រោយរបស់ឈ្មោះ **វល័ក្ខ** ខ្លួនបានប្រាប់ទៅឈ្មោះ [redacted] **សីហា** ថាមើលទៅដូចទំនង ហើយខ្លួនប្រាប់ទៅឈ្មោះ [redacted] **សីហា** ថាឱ្យយកទូរស័ព្ទនៅក្នុងហៅប៉ៅខោមនុស្សស្រីនោះទៅ ខ្លួនបានជិះម៉ូតូទៅក្បែរម៉ូតូរបស់ឈ្មោះ **វល័ក្ខ** ហើយឈ្មោះ [redacted] **សីហា** បានលូកយកទូរស័ព្ទពីក្នុងហោប៉ៅខោក្រោយឈ្មោះ **វល័ក្ខ** ។ មនុស្សស្រីនោះបានស្គាល់ខ្លួនដែរ ព្រោះពេលនោះខ្លួនបានសើចដាក់ បន្ទាប់មកឈ្មោះ [redacted] **សីហា** បានបោះទូរស័ព្ទលើស្មៅចញ្ចើមថ្នល់ដើម្បីប្រគល់ឱ្យម្ចាស់គេវិញ ។ ក្រោយពេលបោះទូរស័ព្ទហើយ ខ្លួនបានស្រែកប្រាប់ទៅម្ចាស់ទូរស័ព្ទថា នោះទូរស័ព្ទបោះទៅលើស្មៅហើយ ។ ខ្លួននិងឈ្មោះ [redacted] **សីហា** បានបន្តដំណើរទៅមុខទៀត ហើយបានបើកបំបុកប៉ារ៉ាស់ប៉ូលិស មូលហេតុដែលខ្លួនបើកបុកនោះដោយសារតែឈ្មោះ [redacted] **សីហា** មិនបានពាក់មួកសុវត្ថិភាពខ្លាចប៉ូលិសផាក បន្ទាប់មកក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបានទាំងពីរនាក់ ។

- ជនជាប់ចោទឈ្មោះ[redacted]**សីហា** បានឆ្លើយថា នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៩ ព្រឹក ឈ្មោះ[redacted]**តុងតុង** បានយកខ្លួននៅផ្ទះទៅញ៉ាំអាហារនៅវីថប់ មុំវិទ្យាល័យហ៊ុនសែនសៀមរាប ។ លុះដល់ម៉ោង ១១ ព្រឹក ថ្ងៃខែឆ្នាំដដែល ខ្លួននិងឈ្មោះ[redacted]**តុងតុង** នាំគ្នាជិះម៉ូតូម៉ាកហុងដា ស៊េរីឆ្នាំ២០១០ ផ្លាកលេខមិនចាំ ជាម៉ូតូរបស់ឈ្មោះ[redacted]**តុងតុង** ដោយឈ្មោះ[redacted]**តុងតុង** ជាអ្នកឌុបខ្លួនទៅយកមិត្តភក្តិឈ្មោះ [redacted] **លីឈាន** នៅខេត្តកំពង់ធំ ។ ពេលធ្វើដំណើរតាមផ្លូវជិតដល់ផ្សារដំដែក ខ្លួននិងឈ្មោះ **តុងតុង** បានឃើញនារីម្នាក់ជិះម៉ូតូម៉ាកហុងដា មិនចាំស៊េរី ហើយនារីម្នាក់នោះឈ្មោះ **តុងតុង** អ្នកស្គាល់ ហើយនារីម្នាក់នោះបានទុកទូរស័ព្ទនៅក្នុងហោប៉ៅខោខាងឆ្វេងខាងក្រោយ ពេលនោះឈ្មោះ **តុងតុង** បានជិះម៉ូតូទៅក្បែរម្នាក់ស្រីនោះ ខ្លួនក៏ធ្វើសកម្មភាពដកហូតយកទូរស័ព្ទនោះតែម្តង ។ ពេលដកហូតយកទូរស័ព្ទបានខ្លួននិងឈ្មោះ **តុងតុង** ជិះម៉ូតូយឺតៗនោះទេ ហើយនារីនោះក៏ជិះតាមក្រោយ បានស្រែកហៅខ្លួនសុំទូរស័ព្ទពីខ្លួនវិញ និងថាកុំលេងសើចច្រើនពេក ខ្លួនក៏បោះទូរស័ព្ទឱ្យគាត់វិញទៅលើស្មៅ ហើយក៏ជិះម៉ូតូហួសទៅផុតផ្សារដំដែក ហើយឈ្មោះ **តុងតុង** បានបើកបុកប៉ារ៉ាស់ប៉ូលិស ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

- តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វល័ក្ខ** បានឆ្លើយនៅដំណាក់កាលស៊ើបសួរបានឆ្លើយថា នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១១ព្រឹក ខ្លួនជិះម៉ូតូម៉ាកហុងដា សេ ១២៥ ស៊េរីឆ្នាំ២០១៥ ពណ៌ខ្មៅ ផ្លាកលេខ សៀមរាប 1T-4011 ចេញពីភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ត្រឡប់ទៅផ្ទះខ្លួនវិញ ស្ថិតនៅភូមិក្បួន ឃុំខ្វាស់ ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ ពេលខ្លួនជិះម៉ូតូតែម្នាក់ឯងដល់ចំណុចភូមិអន្លង់ពីរ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ស្រាប់តែឈ្មោះ[redacted]**តុងតុង** ឌុបមិត្តភក្តិគេម្នាក់ខ្លួនមិនស្គាល់ទេ ហើយមិត្តភក្តិរបស់គេដែលជិះក្រោយក៏ដកទូរស័ព្ទម៉ាក VIVO ពណ៌ក្រហម ដាក់ស្រោមពណ៌ខ្មៅ ពីហោប៉ៅក្រោយខ្លួន ហើយគេក៏ជិះម៉ូតូទៅតិចៗរួចអ្នកបើកម៉ូតូនោះ បើកកញ្ចក់មួកសុវត្ថិភាព ទើបខ្លួនស្គាល់ថាឈ្មោះ **តុងតុង** ពេលនោះខ្លួនក៏ជិះម៉ូតូតាមពីក្រោយរួចនិយាយថា សុំទូរស័ព្ទវិញមកកុំលេងច្រើនពេក ស្រាប់តែអ្នកជិះម៉ូតូពីក្រោយ បោះទូរស័ព្ទខ្លួនទៅលើស្មៅនៅចញ្ចើមផ្លូវក្បែរប៉ុស្តិ៍ប៉ូលិស ខ្លួនមិនបានឈប់ម៉ូតូរើសទូរស័ព្ទនោះទេ គឺខ្លួនជិះម៉ូតូហួសទៅចូលប៉ុស្តិ៍ប៉ូលិសតែ

ម្តង ព្រោះខ្លួនមានជីតាធ្វើជាប៉ូលិសនៅទីនោះ ។ ពេលដល់ប៉ុស្តិ៍ ខ្លួនប្រាប់ថាតាជួយកាក់ម៉ូតូម៉ាកហុងដា សេ ១២៥ ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ 1AQ-4962 បើកបរដោយគ្នាពីរនាក់ឱ្យមកជួយរកទូរស័ព្ទខ្លួន និងសុំទោសខ្លួនវិញ ។ ព្រោះពេលគេបោះទូរស័ព្ទខ្លួននោះ មិនដឹងថាបោះចោលត្រង់កន្លែងណា ។ បន្ទាប់មកពួកគេទាំងពីរនាក់ជិះម៉ូតូទៅបុកប៉ារ៉ាស់សមត្ថកិច្ច ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន និងនាំមកអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង ហើយពួកគេក៏នាំខ្លួនទៅរើសទូរស័ព្ទវិញ ពេលនោះទូរស័ព្ទខ្លួនបែកអេក្រង់ ខ្លួនខឹង ក៏ប្តឹងសមត្ថកិច្ចដើម្បីព្រមានអ្នកទាំងពីរ ដោយមិនដឹងថាគេចាប់គាត់ដាក់គុកបែបនេះសោះ ។ សំណូមពរឱ្យចៅក្រមស៊ើបសួរជួយដោះលែងពួកគាត់វិញ ដើម្បីឱ្យពួកគាត់បានចូលរៀនវិញ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមក ក្នុងរឿងនេះឃើញថាកាលពីថ្ងៃទី៥ ខែមករា ឆ្នាំ ២០២២ ពិតជាមានសកម្មភាពដកហូតទូរស័ព្ទដោយជនជាប់ចោទពីរនាក់នេះ ពេលបានដកហូតទូរស័ព្ទបានហើយបានបើករត់គេចខ្លួន និងពេលដែលឃើញប៉ូលិសខ្លួនបានបោះទូរស័ព្ទចោល និងបានបើកបុកប៉ារ៉ាស់ប៉ូលិសដើម្បីរត់គេច ប៉ុន្តែខ្លួនក៏បានសមត្ថកិច្ចឃាត់ខ្លួនពេលនោះតែម្តង ។ ឃើញថានាពេលសវនាការចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់នេះ ពិតជាមានភាពស៊ីសង្វាក់ជាមួយនឹងចម្លើយដែលខ្លួនបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ហើយព្រមទាំងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ពិតជាមានភាពស៊ីសង្វាក់គ្នាផងដែរ ។ ចម្លើយបដិសេធរបស់ជនជាប់ចោទទាំងពីរនាក់នេះបានឆ្លើយនៅក្នុងរឿងនេះ ឃើញថាពុំមានភស្តុតាងគ្រប់គ្រាន់នោះទេ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ និងស្នើសុំឲ្យតុលាការផ្តន្ទាទោសជនទាំងពីរតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] និងឈ្មោះ [redacted] តុងតុង

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមកឃើញថា កូនក្តីខ្លួនឆ្លើយបដិសេធចំពោះការចោទប្រកាន់ក៏ដូចជាអង្គហេតុ របស់តំណាងអយ្យការ ហើយក្រោយពីបានសួរចម្លើយ ឃើញថានៅថ្ងៃកើតហេតុកូនក្តីខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] តុងតុង នៅពេលដែលជិះម៉ូតូនោះកូនក្តីខ្លួនបានពិភាក្សាគ្នាថាយកដកយកទូរស័ព្ទក្នុងគោលបំណងលេងសើចនោះទេ ហើយក៏ដូចចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយដែរ មូលហេតុដែលគាត់ប្តឹងគឺគោលបំណងចង់ឲ្យកូនក្តីខ្លួនសូមទោសខ្លួនតែប៉ុណ្ណោះ មិនមែនចង់ឲ្យសមត្ថកិច្ច ឬតុលាការផ្តន្ទាទោសដល់កូនក្តីខ្លួនទេ នេះគឺជាអង្គហេតុនៅពេលសវនាការ ។ ហើយចំពោះចម្លើយកូនក្តីខ្លួននាពេលសវនាការបានឆ្លើយបដិសេធ ដោយសារនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បង្ខំឲ្យកូនក្តីខ្លួនឆ្លើយហើយដោយសារមានការធ្វើទារុណកម្ម និងធ្វើបាបទៅលើរាងកាយកូនក្តីខ្លួនពីប៉ូលិស ។ តាមចម្លើយរបស់ដើមបណ្តឹងបានឆ្លើយថាប៉ូលិសដែលឃាត់ខ្លួនកូនក្តីខ្លួនត្រូវជាជីតារបស់ដើមបណ្តឹង អ៊ីចឹងអាចជីតារបស់ដើមបណ្តឹងរដ្ឋប្បវេណីខឹងសម្បារដែលកូនក្តីខ្លួនបានដកហូតទូរស័ព្ទ ។ នៅដំណាក់កាលចៅក្រមស៊ើបសួរ និងនៅពេលសវនាការនេះ កូនក្តីខ្លួនបានឆ្លើយថាការដកហូតទូរស័ព្ទនេះគឺគ្រាន់តែជាការលេងសើចតែប៉ុណ្ណោះ ហើយមិនមានចេតនាយកធ្វើជាកម្មសិទ្ធិ ឬក៏យកមកធ្វើការលក់ដូរ ឲ្យខុសនឹងមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ នោះដែរ ហើយវាគ្រាន់តែជាការលេងសើច ។ មួយវិញទៀត បើយើងមើលអំពីចេតនារបស់គាត់ ធម្មតាក្រុមប្រឹក្សាគាត់បានដឹងហើយថាបើការឆក់ បានទូរស័ព្ទហើយគាត់បើកគេចខ្លួនបាត់ហើយ មិនមែនបើកយឺតៗហើយនៅលេងសើច ក្បែរៗគ្នានោះទេ ហើយជនរងគ្រោះ និងជនជាប់ចោទទាំងពីរនាក់នៅក្បែរគ្នា ហើយនៅឆ្លើយឆ្លងគ្នានោះទេ ។ បើយើងនិយាយពីធាតុផ្សំនៃបទល្មើស



Scanned with CamScanner

ចេតនា គឺមិនមានទេ ហើយចេតនាចង់ដកហូតមកធ្វើជាកម្មសិទ្ធិក៏មិនមានទេ ។ បើយើងវិភាគលើចំណុចនឹង បើយើងវិភាគមើលគឺអត់មាន ហើយមើលព្យសនកម្មនៃជនរងគ្រោះ ធ្ងន់ធ្ងរអ្វីដែរ ហើយបើយើងនិយាយអំពីបទល្មើសទូរស័ព្ទមួយតូចបំផុត បើគិតអំពីលុយវិញការដកហូតនេះបើយកទៅលក់ គឺលក់មិនបាន ៥០ (ហាសិប) ដុល្លារអាមេរិក អីផង អីចឹងព្យសនកម្មនេះវាតូចបំផុត បើយកជនជាប់ចោទទាំងពីរនាក់នេះមកដាក់ពន្ធនាគារវាមិនសមនឹងច្បាប់ តែបើគិតពីឧត្តមប្រយោជន៍របស់កុមារ និងគិតអំពីប្រយោជន៍របស់ជនរងគ្រោះ ខ្លួនគិតថាមិនមានភាពសមហេតុសមផលទៅនឹងអំពើរបស់ពួកគាត់នោះទេ ។ បើយើងមើលទៅលើមាត្រា៥ ចំណុច៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន សមត្ថកិច្ចពាក់ព័ន្ធអំពីអនីតិជន ទាក់ទងនឹងការឃាត់ខ្លួន ការឃុំខ្លួនអនីតិជន និងការផ្តន្ទាទោសនោះគឺឲ្យមានរយៈពេលខ្លីបំផុត នៅក្នុងចំណុចនឹងយើងមើលទៅកូនក្តីខ្លួនមិនបានប្រព្រឹត្តបទល្មើសដូចអ្វីដែលជាការចោទប្រកាន់នោះទេ អីចឹងបូកទាំងអង្គហេតុនិងអង្គច្បាប់មើលឃើញថាពុំមានជាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ទៅលើកូនក្តីខ្លួនទេ ដូច្នេះស្នើសុំឲ្យតុលាការធ្វើការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់ ។

**សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] តុងតុង**

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមក ខ្លួនឯកភាពតាមការសន្និដ្ឋានរបស់លោកមេធាវី [redacted] ដែលបានលើកឡើង តែខ្លួនសុំបន្ថែមខ្លឹមសារអំពីទំនាក់ទំនងអង្គហេតុដែលនាំឲ្យមានករណីនេះកើតឡើងគឺ ដោយសារមានទំនាក់ទំនងរវាង [redacted] តុងតុង ជាមួយជនរងគ្រោះឈ្មោះ [redacted] ល័ក្ខ ពិតប្រាកដមែន ។ បើយោងតាមកំណត់ហេតុស្តាប់ចម្លើយរបស់ជនរងគ្រោះ និងកំណត់ស្តាប់ចម្លើយរបស់ឈ្មោះ [redacted] តុងតុង នៅដំណាក់កាលចៅក្រមស៊ើបសួរ ដែលទំនាក់ទំនងនេះយើងអាចកត់សម្គាល់ថា អាចជាការលេងសើច ហើយបើយើងមើលទៅលើចេតនារបស់ជនជាប់ចោទ ជាទូទៅជនល្មើសបើប្រព្រឹត្តបទល្មើសពិតមែន ប្រាកដណាស់បើកម៉ូតូគេចខ្លួនហើយ មិនមែននៅជិះម៉ូតូក្បែរគ្នា ហើយនៅជជែក និងលេងសើចជាមួយគ្នាបានទេ ។ ខ្លួនយល់ឃើញថាក្នុងរឿងនេះពុំមានជាតុផ្សំគ្រប់គ្រាន់ក្នុងការដាក់បន្ទុកទៅលើកូនក្តីខ្លួនឈ្មោះ [redacted] តុងតុង ពីបទអំពើលួចបានដែរ ដូច្នេះខ្លួនស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតបទចោទ ដើម្បីឲ្យកូនក្តីខ្លួនឲ្យត្រឡប់ទៅជួបអាណាព្យាបាលគាត់វិញ។

**សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] តុងតុង**

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមក ក្រោយពីការស្តាប់កំណត់ស្តាប់ចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ឃើញថាកូនក្តីខ្លួនឈ្មោះ [redacted] តុងតុង បានឆ្លើយបដិសេធនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌នោះដែរ ហើយចម្លើយដែរគាត់បានឆ្លើយគឺកើតចេញពីការប្រើហិង្សា ហើយនៅត្រង់ចំណុចនេះអង្គហេតុផ្អែកទៅលើ**មាត្រា៣៥៣** និង**មាត្រា៣៥៦** អំពើលួចគឺជាការដកហូតដោយទុច្ចរិតទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែអំពើរបស់ឈ្មោះ [redacted] តុងតុង មិនបានប្រព្រឹត្តទុច្ចរិតនិងធ្វើការដកហូតទូរស័ព្ទពីជនរងគ្រោះធ្វើជាកម្មសិទ្ធិទេ ដោយសារតែឈ្មោះ [redacted] តុងតុង និងជនរងគ្រោះមានទំនាក់ទំនងគ្នា ហើយការដកហូតទូរស័ព្ទរបស់ជនរងគ្រោះគឺដើម្បីឆែកសារក្នុងទំនាក់ទំនងស្នេហា ហើយក៏បានប្រគល់វត្ថុនោះទៅឲ្យជនរងគ្រោះវិញ មិនមានព្យសនកម្មការខូចខាតធ្ងន់ធ្ងរដល់ជនរងគ្រោះទេ ។ កូនក្តីខ្លួនឈ្មោះ [redacted] តុងតុង មិនមានចេតនាក្នុងការដកហូតទូរស័ព្ទរបស់ជនរងគ្រោះមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ហើយគ្មានបំណងចង់ធ្វើឲ្យជន

វងគ្រោះមានរបួសស្នាមនោះដែរ ហើយឈ្មោះ [redacted] តុងតុង គាត់គ្រាន់តែមានសកម្មភាពជិះម៉ូតូបុកប៉ារ៉ាស់ប៉ូលិស ហើយការបុកប៉ារ៉ាស់នោះដោយសារពួកគេមិនបានពាក់មួកសុវត្ថិភាព ទើបពួកគេបើកគេចពីសមត្ថកិច្ចខ្លាចមានការផាកពិន័យ ។ ហើយចេតនារបស់ តុងតុង ប្រសិនបើគាត់មានចេតនា ចង់ដកហូតទ្រព្យសម្បត្តិរបស់ជនរងគ្រោះគាត់មិនអាចយកទូរស័ព្ទទៅបោះចោលក្បែរជនរងគ្រោះទេ ។ ខ្លួនសុំសន្និដ្ឋានថា អំពើរបស់ឈ្មោះ [redacted] តុងតុង ពុំមានធាតុផ្សំគ្រាន់ក្នុងការផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ឡើយ ដោយផ្អែកទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីគាត់ថា ពួកគាត់ធ្លាប់មានទំនាក់ទំនងជាមួយគ្នាហើយការដកហូតទូរស័ព្ទនេះក្នុងគោលដៅលេងសើចនឹងគ្នា ដោយឈ្មោះ [redacted] សីហា មិនព្រមឲ្យទូរស័ព្ទទៅឲ្យឈ្មោះ [redacted] វល័ក្ខ ដោយសន្តិវិធី ដោយសារតែឈ្មោះ [redacted] សីហា ប៉ះទង្គិចលើពាក្យសំដីទើបធ្វើឲ្យឈ្មោះ [redacted] សីហា បោះទូរស័ព្ទទៅឲ្យឈ្មោះ [redacted] វល័ក្ខ វិញ នៅក្នុងនឹងខ្លួនសុំសំណូមពរឲ្យតុលាការមេត្តាសម្រេចឲ្យឈ្មោះ [redacted] តុងតុង និងឈ្មោះ [redacted] សីហា រួចផុតបទចោទ យោងតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងស្នើសុំឲ្យតុលាការសម្រេចដោះលែងកូនក្តីខ្លួនឈ្មោះ [redacted] តុងតុង និងឈ្មោះ [redacted] សីហា ឲ្យបានត្រឡប់ទៅវិញ ដើម្បីបានជួបជុំក្រុមគ្រួសារ និងបានបន្តការសិក្សាវិញ ដោយផ្អែកលើឧត្តមប្រយោជន៍របស់កុមារ ។ ហើយការឃុំខ្លួនចុងក្រោយគឺជាជម្រើសប៉ុណ្ណោះ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

- ជនជាប់ចោទឈ្មោះ [redacted] សីហា សំណូមពរសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង ដើម្បីឲ្យខ្លួនមានសេរីភាព និងបានបន្តការសិក្សា ។

- ជនជាប់ចោទឈ្មោ [redacted] តុងតុង សំណូមពរសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង ដើម្បីឲ្យខ្លួនមានសេរីភាព និងបានបន្តការសិក្សា ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងការប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១/-ឈ្មោះ [redacted] តុងតុង និងឈ្មោះ [redacted] សីហា ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ លួច តាមរយៈដីកាដំណោះស្រាយលេខ ១៣៨៤ ពស.ព្រស/ឋ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ពាក់ព័ន្ធនឹងសកម្មភាពដកហូតទូរស័ព្ទរបស់ឈ្មោះ [redacted] វល័ក្ខ ដែលបានទុកនៅហោប៉ៅខោក្រោយ ពិតប្រាកដមែន ។

២/-ចម្លើយបដិសេធរបស់ជនជាប់ចោទ នាពេលសវនាការបានឆ្លើយថា ខ្លួនត្រូវបានសមត្ថកិច្ចបង្ខំឲ្យខ្លួនឆ្លើយ ហើយខ្លួនយកទូរស័ព្ទរបស់ឈ្មោះ [redacted] វល័ក្ខ គ្រាន់តែជាការលេងសើច មិនឲ្យតុលាការជឿបានទេ ដោយហេតុថាចម្លើយសារភាពរបស់ជនជាប់ចោទ នៅចំពោះមុខចៅក្រមស៊ើបសួរ អយ្យការ មន្ត្រីនគរបាលយុត្តិធម៌ រួមទាំងរបាយការណ៍សំយោគ និងភស្តុតាងនានាដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌



Scanned with CamScanner

នៅតែអាចឲ្យជឿបានថា ជនជាប់ចោទទាំងពីរនាក់នេះពិតជាបានប្រព្រឹត្តបទល្មើស ដូចការបញ្ជូនមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ប្រាកដមែន ។

៣/-ជនជាប់ចោទជាអនីតិជន ហើយពុំមានសញ្ញាណណាមួយនាំឲ្យមានការសង្ស័យអំពីបញ្ញាស្មារតីឡើយ ដូច្នេះជនជាប់ចោទត្រូវតែទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួនត្រឹមកម្រិតជនន់លួមច្បាប់បានកំណត់ ។

៤/-ជនជាប់ចោទបានធ្វើសកម្មភាពដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃ មកធ្វើជារបស់ខ្លួនទាល់តែជនរងគ្រោះដេញតាមទើបប្រគល់ឲ្យវិញ ដែលនាំឲ្យខូចប្រយោជន៍ដល់ជនរងគ្រោះ ដែលច្បាប់បញ្ញត្តថាជាបទល្មើស និងត្រូវផ្តន្ទាទោស ។

៥/-អំពើរបស់ជនជាប់ចោទបានប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គម ។

៦/-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ និងស្នើសុំឲ្យតុលាការផ្តន្ទាទោសជនទាំងពីរនេះតាមច្បាប់ ដែលគប្បីតុលាការលើកមកពិចារណា ។

៧/-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ គប្បីតុលាការមិនលើកយកមកពិចារណាទេ ដោយហេតុថាតុលាការឃើញថាមានអង្គហេតុ ដកហូតយកទូរស័ព្ទរបស់ជនរងគ្រោះ ដោយគ្មានការអនុញ្ញាត ហើយចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលមន្ត្រីនគរយុត្តិធម៌ អយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ នៅតែមានទម្ងន់ជាងហើយជឿថាជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទលួច ប្រាកដមែន ។

៨/-ផ្អែកតាមអង្គហេតុ ភស្តុតាងនានាដែលដាក់បន្ទុកនិងចម្លើយរបស់ជនជាប់ទាក់ទិននាពេលសវនាការខាងលើ ឃើញថាអំពើប្រព្រឹត្តរបស់ជនជាប់ចោទរបស់ឈ្មោះ [redacted] **តុងតុង** និងឈ្មោះ [redacted] **សីហា** បានបំពេញជាតុផ្សំគ្រប់គ្រាន់ ពីបទ **លួច** តាមបញ្ញត្តិ**មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ**។

៩/-មានភស្តុតាងលើសពីវិមតិសង្ស័យ និងជាតុផ្សំបទល្មើសគ្រប់គ្រាន់ បង្ហាញថាជនជាប់ចោទឈ្មោះ [redacted] **តុងតុង** ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានពិរុទ្ធភាពពីបទ **លួច** ប្រព្រឹត្តនៅភូមិអន្លង់ពីរ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ**។

១០/-វត្ថុតាងចាប់យកដែលមាននៅក្នុងដីកាបង្គាប់ឱ្យរក្សាទុកវត្ថុចាប់យកលេខ ០៦ វត.ព្រទ/២០២២ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ រួមមាន ម៉ូតូ HONDA DREAM ស៊េរីឆ្នាំ២០១០ ពណ៌ខ្មៅ ពាក់ផ្លាកលេខភ្នំពេញ 1AO-6962 លេខតួ-លេខម៉ាស៊ីន 847644 (អត់កញ្ចក់ អត់កន្ត្រក បែកកញ្ចក់អំពូលភ្លើង) មានកូនសោ ចំនួន១គ្រឿង គប្បីត្រូវសម្រេចរឹបអូស ។ ដោយឡែក ទូរស័ព្ទដៃម៉ាក HUAWEI មិនស្គាល់ MODEL ពណ៌ខ្មៅ (បែកកញ្ចក់មុខ) ចំនួន១គ្រឿង ទូរស័ព្ទដៃម៉ាក SAMSUNG មិនស្គាល់ MODEL ពណ៌ខ្មៅ (បែកកញ្ចក់មុខ) ចំនួន១គ្រឿង កាបូបលុយ ពណ៌ខ្មៅ (មាន VISA CARD ABA ចំនួន១ កាត ABA ចំនួន១ ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ចំនួន១) ចំនួន១ គប្បីសម្រេចប្រគល់ម្ចាស់ដើមវិញ ។

**១១-**តាមស្ថានភាពរបស់ជនជាប់ចោទ និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស សំណូមពរសុំឲ្យតុលាការរកយុត្តិធម៌ឲ្យខ្លួន និងឆាប់បានទៅការការសិក្សាវិញ តាមស្ថានភាពបែប



Scanned with CamScanner

នេះ ដែលគប្បីតុលាការពិនិត្យ ពិចារណា សម្រេចផ្តន្ទាទោសលើជនជាប់ចោទនេះ ក្នុងកម្រិតធួនល្មមតាមច្បាប់កំណត់ ។

## សាលាដំបូងខេត្តសៀមរាប

## ហេតុដូច្នេះសម្រេច

១/- ផ្តន្ទាទោសជនជាប់ចោទ ៖

ក- ឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **៦ (ប្រាំមួយ) ខែ**

ខ- ឈ្មោះ [redacted] **តុងតុង** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **៦ (ប្រាំមួយ) ខែ**

ពីបទ **លួច (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅភូមិអន្លង់ពីរ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ** ។

២/- វត្ថុតាងចាប់យកដែលមាននៅក្នុងដីកាបង្គាប់ឱ្យរក្សាទុកវត្ថុចាប់យកលេខ ០៦ វត.ព្រទ/២០២២ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ រួមមាន ៖

ក- ម៉ូតូ HONDA DREAM ស៊េរីឆ្នាំ២០១០ ពណ៌ខ្មៅ ពាក់ស្លាក់លេខ ភ្នំពេញ 1AO-6962 លេខតួ-លេខម៉ាស៊ីន 847644 (អត់កញ្ចក់ អត់កន្ត្រក បែកកញ្ចក់អំពូលភ្លើង) មានកូនសោ ចំនួន១ គ្រឿង **ត្រូវរឹបអូស** ។

ខ- ទូរស័ព្ទដៃម៉ាក HUAWEI មិនស្គាល់ MODEL ពណ៌ខ្មៅ (បែកកញ្ចក់មុខ) ចំនួន១គ្រឿង ទូរស័ព្ទដៃម៉ាក SAMSUNG មិនស្គល់ MODEL ពណ៌ខ្មៅ (បែកកញ្ចក់មុខ) ចំនួន១គ្រឿង និងកាបូបលុយពណ៌ខ្មៅ (មាន VISA CARD ABA ចំនួន១ កាត ABA ចំនួន១ ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ចំនួន១) ចំនួន១ **ប្រគល់ឲ្យម្ចាស់ដើមវិញ** ។

សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

**"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"**

ថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

ខេត្តសៀមរាប ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

| បានឃើញ<br>**ប្រធានក្រុមប្រឹក្សា** | **ក្រឡាបញ្ជី** |
|---|---|
| [redacted] | [redacted] |



Scanned with CamScanner